ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.......................................................

ផ្នែកទំនាក់ទំនង, ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ: (៨៥៥-២៣) ៩៩០ ១៩៦
អ៊ីម៉ែល: nbccommunication@nbc.org.kh

កំពង់ចាម, ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៦

# សេចក្តីប្រកាសព័ត៌មាន

នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៦ ធនាគារជាតិនៃកម្ពុជាបានរៀបចំសន្និបាតបូកសរុបលទ្ធផលការងាររបស់ធនាគារជាតិនៃកម្ពុជាប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១៦ នៅសាខាធនាគារជាតិនៃកម្ពុជា ខេត្តកំពង់ចាម ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ។ សន្និបាតធនាគារជាតិនៃកម្ពុជាត្រូវបានធ្វើឡើងក្នុងគោលបំណងអបអរសាទរ និងផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយអំពីលទ្ធផលដែលធនាគារជាតិនៃកម្ពុជាទទួលបានកន្លងមកនិងទិសដៅការងារ ដើម្បីឈានទៅសម្រេចឱ្យបានជោគជ័យថ្មីៗបន្ថែមទៀត ។

នៅឆមាសទី១ ឆ្នាំ២០១៦នេះ កំណើនសេដ្ឋកិច្ចពិភពលោកបានបន្តងើបឡើងក្នុងល្បឿនយឺត និងប្រឈមភាពមិនច្បាស់លាស់ខ្ពស់ជាងមុន ក្រោយពីការសម្រេចចិត្តចាកចេញរបស់ប្រទេសអង់គ្លេសពីសហភាពអឺរ៉ុប (Brexit) ។

នៅកម្ពុជា ក្នុងឆមាសទី១នេះ សកម្មភាពសេដ្ឋកិច្ចមានជវភាពល្អប្រសើរក្នុងស្ថានភាពដែលស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចត្រូវបានបន្តរក្សាយ៉ាងរឹងមាំ ។ លទ្ធផលនេះទទួលបានដោយសារកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការធ្វើកំណែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យ, ការធ្វើពិពិធកម្មលើមូលដ្ឋានសេដ្ឋកិច្ច និងការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចសមស្រប ដើម្បីធ្វើឱ្យប្រសើរឡើងនូវបរិយាកាសវិនិយោគជំរុញពាណិជ្ជកម្ម និងអភិវឌ្ឍវិស័យចម្បងៗតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ច្បាស់លាស់ ។



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ក្នុងនាមជាអាជ្ញាធររូបិយវត្ថុនិងអាជ្ញាធរត្រួតពិនិត្យប្រព័ន្ធធនាគារ ធនាគារជាតិនៃកម្ពុជាបានរួមចំណែកគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចជាតិ តាមរយៈការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងអភិវឌ្ឍវិស័យធនាគារប្រកបដោយបរិយាប័ន្ននិងសមាហរណកម្ម ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ឆ្នាំ២០១៣-២០១៨ ដើម្បី កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០ ។

អត្រាអតិផរណាមានកម្រិតជាមធ្យម ២,៨% នៅឆមាសទី១ នេះ ហើយអត្រាប្តូរប្រាក់មានស្ថិរភាពក្នុងរង្វង់ ៤.០៥៤រៀល ក្នុងមួយដុល្លារអាមេរិក ។ ទន្ទឹមនេះ ទុនបម្រុងអន្តរជាតិបានកើនដល់ ៥,៥ ប៊ីលានដុល្លារអាមេរិក ដែលអាចធានាការទូទាត់ទំនិញនិងសេវាបានប្រមាណ ៥ខែ ខ្ពស់ជាងកម្រិតអប្បបរមាដែលប្រទេសកំពុងអភិវឌ្ឍន៍គួរមាន (៣ខែ) ។

ការរីកចម្រើននៃប្រព័ន្ធធនាគារកម្ពុជាបានរួមចំណែកយ៉ាងសំខាន់ ក្នុងការគាំទ្រការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ចនិងជំរុញកំណើន ។ នៅឆមាសទី១នេះ ទ្រព្យសកម្មរបស់ប្រព័ន្ធធនាគារបានកើនឡើងប្រមាណ ២,២ ប៊ីលានដុល្លារអាមេរិក ដែលបានធ្វើឱ្យទ្រព្យសកម្មសរុបកើនឡើងដល់ប្រមាណ ២៦ ប៊ីលានដុល្លារអាមេរិក ស្មើនឹង ១៣១% នៃផ.ស.ស ។ ទន្ទឹមនេះ ប្រាក់បញ្ញើសរុបបានកើនដល់ ៦៧% នៃផ.ស.ស ហើយឥណទានសរុបបានកើនឡើងដល់ ៨០% នៃផ.ស.ស ដែលត្រូវបានបែងចែកប្រកបដោយប្រសិទ្ធភាពទៅវិស័យសេដ្ឋកិច្ចចម្បងៗ ។

ក្នុងការរួមចំណែកអនុវត្តគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ធនាគារជាតិនៃកម្ពុជាបានបន្តលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ ដើម្បីពង្រីកការផ្តល់សេវាហិរញ្ញវត្ថុឱ្យកាន់តែទូលំទូលាយក្នុងតម្លៃសមរម្យ ដល់ប្រជាជនក្រីក្រ ជាពិសេស តាមរយៈការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ ។ មូលនិធិអភិវឌ្ឍន៍មូលធនអង្គការសហប្រជាជាតិ (UNCDF) បានបានអបអរសាទរចំពោះកម្ពុជា ដែលសម្រេចបានការពង្រីកការផ្តល់សេវាហិរញ្ញវត្ថុដល់ប្រជាជនពេញវ័យយ៉ាងឆាប់រហ័សនាពេលកន្លងមក ដោយប្រជាជនពេញវ័យប្រមាណ ៧១% នៅកម្ពុជាកំពុងប្រើប្រាស់សេវាហិរញ្ញវត្ថុ ដែលក្នុងនោះ ៥៥% ប្រើប្រាស់សេវាផ្លូវការ ។

ស្របពេលដែលស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិភពលោកកាន់តែមានភាពប្រទាក់ក្រឡា ហើយប្រព័ន្ធធនាគារកម្ពុជាកាន់តែមានសមាហរណកម្មខ្ពស់ ធនាគារជាតិនៃកម្ពុជាបានពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិទាំងក្នុងក្របខណ្ឌតំបន់និងពិភពលោក ហើយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ក៏បានពង្រឹងប្រសិទ្ធភាពនៃការទប់ស្កាត់សកម្មភាពសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មក្នុងប្រព័ន្ធធនាគារផងដែរ ។ ទន្ទឹមនេះ ការគ្រប់គ្រងផ្ទៃក្នុងត្រូវបានពង្រឹង ហើយសមត្ថភាពធនធានមនុស្សលើផ្នែកឯកទេសកម្មចំណេះដឹង

បច្ចេកទេសត្រូវបានអភិវឌ្ឍជាលំដាប់ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងាររបស់មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា ។

ចំពោះទស្សនវិស័យលើស្ថានភាពសេដ្ឋកិច្ចកម្ពុជា កំណើនរំពឹងថានឹងសម្រេចបានក្នុងអត្រាប្រមាណ ៧,១% នៅឆ្នាំ២០១៦នេះ ជាមួយនឹងអត្រាទាបនៃអតិផរណាប្រមាណក្រោម ៣% និងស្ថិរភាពអត្រាប្តូរប្រាក់ក្នុងរង្វង់ ៤.០៥០ រៀលក្នុងមួយដុល្លារអាមេរិក ។ ទន្ទឹមនេះ ប្រព័ន្ធនាគារនឹងបន្តអភិវឌ្ឍយ៉ាងរឹងមាំនិងដើរតួនាទីកាន់តែសំខាន់ក្នុងការគាំទ្រនិងជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ។

ទោះជាយ៉ាងណា ក្នុងបរិការណ៍ដែលស្ថានភាពទីផ្សារហិរញ្ញវត្ថុអន្តរជាតិកំពុងតែប្រឈមនឹងភាពមិនច្បាស់លាស់ ហើយប្រព័ន្ធធនាគារកម្ពុជាមានការរីកចម្រើនយ៉ាងឆាប់រហ័ស ធនាគារជាតិនៃកម្ពុជាបានតាមដានយ៉ាងយកចិត្តទុកដាក់លើការវិវត្តនានា និងបានដាក់ចេញនូវវិធានការមីក្រូនិងម៉ាក្រូប្រុងប្រយ័ត្ន ដែលមានលក្ខណៈបុរេសកម្មជាបន្តបន្ទាប់ដើម្បីគ្រប់គ្រងហានិភ័យជាប្រព័ន្ធដែលអាចកើតឡើងជាយថាហេតុ ផ្អែកលើយន្តការទីផ្សារ និងមានលក្ខណៈទន់ភ្លន់ សំដៅរក្សាស្ថិរភាពហិរញ្ញវត្ថុឱ្យបានរឹងមាំ ។

ម៉្យាងទៀត កម្រិតខ្ពស់នៃដុល្លារូបនីយកម្មនៅតែបន្តដាក់កំហិតលើប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយរូបិយវត្ថុ ។ ឆ្លើយតបនឹងបញ្ហានេះ ធនាគារជាតិនៃកម្ពុជាបាន និងកំពុង i/- អភិវឌ្ឍទីផ្សារអន្តរធនាគារនិងរូបិយវត្ថុ តាមរយៈការជំរុញតម្រូវការលើមូលបត្រអាចជួញដូរបាន (NCD) ដើម្បីពង្រឹងការគ្រប់គ្រងសន្ទនីយភាពនៅក្នុងប្រព័ន្ធធនាគារ និងបង្កើតឧបករណ៍គោលនយោបាយរូបិយវត្ថុផ្អែកលើយន្តការទីផ្សារ ii/- អភិវឌ្ឍទីផ្សារប្តូរប្រាក់ដើម្បីឆ្លើយតបនឹងតម្រូវការប្រាក់រៀល ក៏ដូចជាស្រូបយករូបិយប័ណ្ណចូលមកក្នុងប្រព័ន្ធធនាគារ និង iii/- លើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ផ្អែកលើយន្តការទីផ្សារ និងគោលការណ៍ស្ម័គ្រចិត្ត ក្នុងគោលដៅពង្រឹងប្រសិទ្ធភាពនៃគោលនយោបាយរូបិយវត្ថុ ។